**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ: ២៨៧
ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០២

**<u>សាលដីកា</u>**

លេខ:៣៨
ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម **ឌិត មុន្នី** ជាប្រធាន
២-លោក **ស៊ិន ឌឹម** ជាចៅក្រមរបាយការណ៍
៣-លោក **ជីវ កេង** ជាចៅក្រម
៤-លោក **ប្រាក់ គឹមសាន** ជាចៅក្រម
៥-លោក **គង់ ភីរុន** ជាចៅក្រម
៦-លោក **សោម សិរិវឌ្ឍ** ជាចៅក្រម
៧-លោក **យស់ សូខឿន** ជាចៅក្រម
៨-លោក **ឈឹម ស៊ីផល** ជាចៅក្រម
៩-លោក **ប៉ែន សារឿន** ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-អ្នកស្រី **យុត សុគន្ធា**

**<u>តំណាងមហាអយ្យការ</u>**

-លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៤៤ (ក) ចុះថ្ងៃទី០៤-០៧-០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧៣ ចុះថ្ងៃទី២១-១១-០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះឌុច វ៉ាត់(ជាម្ចាស់បណ្តឹងសាទុក្ខ) អាយុ៥១ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅ ភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ផ្ទេរសិទ្ធិឱ្យឈ្មោះ សេង អាន

**មេធាវី លោកចាន់ សុខយាង**

និងចុងចម្លើយឈ្មោះគង់ សាគឿន(ជាចុងបណ្តឹងសាទុក្ខ) ភេទស្រីអាយុ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងសុំគ្រប់គ្រងដី

បានឃើញបណ្ដឹងសាទុក្ខលេខ២៥២ ចុះថ្ងៃទី០៤-០៧-០២ របស់ឈ្មោះឌុច រ៉ាត់ ប្ដឹងមិនសុខចិត្ត នឹងសាលដីកាលេខ៨៤(ក) ចុះថ្ងៃទី០៤-០៧-០២ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៨៧ ចុះថ្ងៃទី១៨-០៩-០២ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះឌុច រ៉ាត់ ចុះថ្ងៃទី១៣-០៩-៩៩ ប្ដឹងទាមទារយកដីដែលមានប័ណ្ណសម្គាល់សិទ្ធិលេខC₈0051 របស់ខ្លួនវិញដោយហេតុថា កាលពីថ្ងៃទី១៥-០១-៩៤ ប្រពន្ធខ្លួនឈ្មោះសេង អាន បានខ្ចីប្រាក់ពីឈ្មោះគង់ សាគឿន និងប្ដីឈ្មោះសេក សំអឿនចំនួន១៥.០០០បាត ដោយធ្វើកិច្ចសន្យាដាក់បញ្ចាំប្លង់ដីរហូតដល់ថ្ងៃទី៣០-០៣-៩៤ ខ្លួនគ្មានប្រាក់សងទៅម្ចាស់ប្រាក់ ម្ចាស់ប្រាក់បង្ខំឱ្យខ្លួនផ្ដិតមេដៃប្រគល់ប្លង់នោះឱ្យទៅម្ចាស់ប្រាក់ ការផ្ដិតមេដៃគឺតែខ្លួនឯងទេ ដោយគ្មានប្រពន្ធចូលរួមឡើយ ។

តាមពាក្យបណ្ដឹងតបចុះថ្ងៃទី៣០-១០-៩៩ របស់ចុងចម្លើយឈ្មោះគង់ សាគឿនថា នៅថ្ងៃទី១៥-០១-៩៤ ឈ្មោះឌុច រ៉ាត់ បានខ្ចីប្រាក់ពីខ្លួនចំនួន១៥.០០០បាត ដោយយកប្លង់ដីមានលេខC₈0051 មកដាក់បញ្ចាំនឹងខ្លួនដោយសន្យាថា បើគ្មានប្រាក់សងទេ នឹងប្រគល់ប្លង់ដីនេះមកឱ្យខ្លួន ។ ការធ្វើកិច្ចសន្យានេះនៅ ចំពោះមុខមេភូមិដោយគ្មានការបង្ខិតបង្ខំពីមជ្ឈដ្ឋានណាឡើយ ។

បានឃើញសាលក្រមលេខ៣៩ ចុះថ្ងៃទី០១-០៣-០០ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលសម្រេច ដូចតទៅ៖

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី១៨-០៩-៩៩ របស់ដើមចោទឈ្មោះឌុច រ៉ាត់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយផ្ទុយនឹងគតិច្បាប់។

២-ទទួលពាក្យបណ្ដឹងតវ៉ាតបចុះថ្ងៃទី៣០-១០-៩៩ របស់ចុងចម្លើយ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

តាមមាត្រា៧៨,១៥០,១៨៤ នៃច្បាប់ភូមិបាលដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ១០០ក្រ ចុះថ្ងៃទី១៣-១០-៩២ ។

៣-ឲ្យឈ្មោះគង់ សាគឿន ជាចុងចម្លើយមានសិទ្ធិពេញលេញតាមច្បាប់ នូវការទទួលគ្រប់គ្រងដីចំការ ដែលមានប័ណ្ណសម្គាល់សិទ្ធិលេខC₈0051 ចុះថ្ងៃទី០៤-០៥-៩៣ បន្ទាប់ពីសាលក្រមនេះមានអានុភាពអនុវត្ត ។

៤-កាត់យកប្រាក់ឈ្មោះឌុច រ៉ាត់ បង់ប្រាក់ប្រដាប់ក្ដី៧០០០៛ ទុកជាប្រយោជន៍ច្បាប់ និងឱ្យបង់ពន្ធសមាមាត្រលើទឹកប្រាក់១៥.០០០បាត(មួយម៉ឺនប្រាំពាន់បាត)អត្រាត្រូវបង់ស្មើ ១៥០បាត (មួយរយហាសិបបាត) ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូភាគី ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ពីរខែ គិតពីថ្ងៃប្រកាសសាលក្រម ។

សាលក្រមនេះត្រូវបានឈ្មោះឌុច រ៉ាត់ ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ២៥ ចុះថ្ងៃទី២៧-០៤-០០ លើសាលក្រមទាំងមូល ។

បានឃើញសាលដីកាលេខ២៣(ឈ) ចុះថ្ងៃទី២១-០៩-០០ របស់សាលាឧទ្ធរណ៍ដែលសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ២៥ ចុះថ្ងៃទី២៧-០៤-០០ របស់ឈ្មោះឌុច រ៉ាត់ ជាដើមចោទ ទុកជា ត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៣៩ ចុះថ្ងៃទី០១-០៣-០០ របស់តុលាការខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣.០០០៛។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

សាលដីកានេះ ត្រូវបានលោកឌុច រ៉ាត់ ប្តឹងសាទុក្ខតាមបណ្តឹងលេខ៣៨៥ ចុះថ្ងៃទី២១-០៩-០០ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ១៣៣ ចុះថ្ងៃទី៣០-០៨-០១ របស់តុលាការកំពូល ដែលមានសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងសាទុក្ខលេខ៣៨៥ ចុះថ្ងៃទី២១-០៩-០០ របស់ឈ្មោះឌុច រ៉ាត់ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៣(ឈ) ចុះថ្ងៃទី២១-០៩-០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៤១១ ចុះថ្ងៃទី១៦-១០-០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោកឌុច រ៉ាត់ បានបង់រួចហើយ គឺ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យអ្នកស្រី គង់ សាគឿន សងប្រាក់ចំនួន១៩០០០៛ នេះទៅលោកឌុច រ៉ាត់ វិញ ។

៥-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី៣០-០៨-០១ ។

បានឃើញសាលដីការបៀបលេខ០១(ក) ចុះថ្ងៃទី១៧-០១-០២ មានខ្លឹមសារដូចតទៅៈ

-ចាត់មន្ត្រីជំនាញឱ្យធ្វើកោសល្យវិច្ច័យលើស្នាមមេដៃ ដែលមាននៅក្នុងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ៣១-០៣-៩៤ ត្រង់ឈ្មោះសេង អាន ដើម្បីផ្ទៀងផ្ទាត់ជាមួយស្នាមមេដៃទាំងអស់ដែលមាននៅក្នុងកំណត់ហេតុផ្តិតម្រាមដៃចុះថ្ងៃទី១៧-០១-០២ របស់សាលាឧទ្ធរណ៍ តើមានស្នាមមេដៃ ណាមួយដែលមាននៅក្នុងកំណត់ហេតុផ្តិតម្រាមដៃចុះថ្ងៃទី១៧-០១-០២ របស់សាលាឧទ្ធរណ៍ ដូចគ្នានឹងស្នាមមេដៃ ដែលមាននៅក្នុងលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី៣១-០៣-៩៤ ត្រង់ឈ្មោះសេង អាន ដែរឬទេ ? បើមានសូមបញ្ជាក់ថា ស្នាមម្រាមដៃណាមួយ ?ដៃឆ្វេង ឬដៃស្តាំ ? របស់ឈ្មោះអ្វី?

ចាត់អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន ឱ្យបញ្ជាក់ និងស្រាវជ្រាវឱ្យដឹងថា ទីតាំងទំនាស់ចាប់តាំងពីថ្ងៃដែលឈ្មោះឌុច រ៉ាត់ (ប្តី) និងឈ្មោះសេង អាន (ប្រពន្ធ) ធ្វើលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី៣១-០៣-៩៤ ឱ្យទៅឈ្មោះសេង សំបឿន តើនៅលើអ្នកណាកាន់កាប់ពីថ្ងៃខែឆ្នាំប៉ុន្មាន? រហូតដល់ពេលណា ?សព្វថ្ងៃនរណាកាន់កាប់ ?និងនៅលើដីទំនាស់មានដំណាំអ្វីខ្លះ ?នរណាដាំ ?ពីពេលណាមក ?សព្វថ្ងៃដំណាំបានទទួលផល ឬនៅ ? អ្នកណាទទួល?

បានឃើញសាលដីកាលេខ១៣(ក) ចុះថ្ងៃទី១១-០៣-០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារដូចតទៅៈ

១-ទទួលជំនុំជំរះរឿងក្តីនេះឡើងវិញតាមអំណាចសាលដីកាលេខ១៣៣ ចុះថ្ងៃទី៣០-០៨-០១ របស់តុលាការកំពូល ។

២-ប្រគល់ដីចំការដែលមានប័ណ្ណសម្គាល់សិទ្ធិលេខC₈0051 ចុះថ្ងៃទី០៤-០៥-៩៣ ឱ្យទៅឈ្មោះគង់ សាភឿន គ្រប់គ្រងជាកម្មសិទ្ធិចាប់ពីពេលសាលដីកានេះចូលជាស្ថាពរ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជី៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងអាជ្ញាធរតុលាការ៥០០០៛ សរុប ១៣០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះ ត្រូវបានឈ្មោះលឹម វណ្ណី ទទួលសិទ្ធិពីឈ្មោះឌុច រ៉ាត់ ប្តឹងទាស់តាមបណ្តឹងលេខ ៤៨ ចុះថ្ងៃទី០៦-០៥-០២ មិនសុខចិត្ត នឹងសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ៤៤(ក) ចុះថ្ងៃទី០៤-០៧-០២ របស់សាលាឧទ្ធរណ៍មានខ្លឹមសារដូចតទៅៈ

១-ទទួលសេចក្តីសុំប្តឹងទាស់ ចុះថ្ងៃទី០៦-០៥-០២ របស់ឈ្មោះលឹម វណ្ណីទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាលេខ១៣(ក) ចុះថ្ងៃទី១១-០៣-០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ២៥២ ចុះថ្ងៃទី០៤-៧-០២ របស់លោកឧុច វ៉ាត់ស្ថិតក្នុងកំណត់ច្បាប់។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច តាមច្បាប់ ។

តុលាការកំពូលបានចេញលិខិតបង្គាប់ ឱ្យម្ចាស់បណ្តឹងសាទុក្ខធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួនរួច ហើយប៉ុន្តែសាមុីខ្លួនពុំបានធ្វើសារណាដាក់ជូនតុលាការកំពូលទេ ដូច្នេះតុលាការកំពូល អាចលើកយករឿងនេះ មកចាត់ការតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសេង អាន នាពេលសវនាការថាៈ ខ្លួនសុំទាមទារយកដីចំការវិញនិងសុំសងប្រាក់ដែលជំពាក់ទាំងប៉ុន្មានទៅចុងម្លើយវិញ ។

បានស្តាប់ចម្លើយរបស់ឈ្មោះគង់ សាភឿន នាពេលសវនាការថា៖ ខ្លួនមិនយល់ព្រមទេ ។ ខ្លួនមិនបានចាប់បង្ខំគាត់ទេ គឺគាត់ធ្វើដោយស្ម័គ្រចិត្ត ។ ដីពេលនោះគ្មានតម្លៃទេ ។ ខ្លួនកាន់កាប់តាំងពី១៩៩៤មក ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកចាន់ សុខឃាង ការពារឱ្យដើមចោទថា៖ ប្រភពដើមគឺជាកិច្ចសន្យា ខ្ចីចងការប្រាក់ ក្រោយមកទើបមានការផ្ទេរកម្មសិទ្ធិទៅម្ចាស់បំណុល ។

សុំតុលាការពិនិត្យទៅលើវិការៈ នៃការផ្ទេរសិទ្ធិនោះ ចុងចម្លើយគ្មានភស្តុតាងក្នុងការផ្ទេរសិទ្ធិទេ ។ គាត់នៅទទួលការប្រាក់ ក្រោយមានការផ្ទេរសិទ្ធិចំនួន៤ខែទៀត ។ ហើយកូនក្តីខ្លួនបានកាន់កាប់ដីនេះរហូតដល់ឆ្នាំ១៩៩៩ ដែលមានសាក្សីមានព្រំដីនៅជាប់នោះជាអ្នកឆ្លើយបំភ្លឺ ។ តម្លៃដីនិងការខ្ចីប្រាក់វាមានការខុសគ្នាឆ្ងាយពេក ។

<u>**សំណូមពរ**</u>

-សុំប្រគល់ដីឱ្យកូនក្តីខ្លួនវិញ និងយល់ព្រមសងប្រាក់និងការប្រាក់រហូតដល់ថ្ងៃកំណត់.

-សុំកាត់ដីពាក់កណ្តាលទៅឱ្យម្ចាស់បំណុល សល់ពាក់កណ្តាលទុកឱ្យកូនក្តីខ្លួនបានបង្កបង្កើនផលផង ។

អ្នកស្រីគង់ សាភឿន បន្ថែមថា៖ លុយនេះជាលុយខ្ចីមិនមែនចងការទេ ខ្លួនមិនអាចចែកបានទេ។ ខ្លួនមិនដែលបានទទួលការប្រាក់ទេ ។ ពេលខ្ចីលុយខ្លួន គឺសន្យាតែពីរខែទេ តែដល់ថ្ងៃកំណត់គាត់គ្មានលុយ គាត់អង្វរឱ្យខ្លួនកាត់ដីយក ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ២៥២ ចុះថ្ងៃទី០៤-០៧-០២ របស់លោកឌុច រ៉ាត់ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តី បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។

-យល់ឃើញថា ការណ៍ដែលមេធាវីដើមចោទលើកឡើង នាពេលសវនាការនេះថា៖ ការផ្ទេរសិទ្ធិដីទំនាស់ពីដើមចោទទៅចុងចម្លើយគឺធ្វើឡើងក្រោមរូបភាពខ្ចីចងការប្រាក់ទេ ដែលតាមច្បាប់ភូមិបាលការផ្ទេរសិទ្ធិនេះពុំអាចយកជាការបានទេ ហើយតាមមាត្រា៥ នៃក្រឹត្យ-ច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី២៨-១០-៨៨កិច្ចសន្យានេះ ត្រូវទុកជាមោឃៈដាច់ខាតនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថាពុំមានភស្តុតាងណាបញ្ជាក់ថា ដីទំនាស់នេះ ជាទ្រព្យដាក់បញ្ចាំក្នុងកិច្ចសន្យាខ្ចីចងការទេ ហើយក៏ពុំមានភស្តុតាងណាថាចុងចម្លើយបានទទួលការប្រាក់ដែរ ។

-យល់ឃើញថា ដើមចោទ និងមេធាវីដើមចោទ បានបដិសេធមិនទទួលស្គាល់មេដៃ ដែលដាក់ឈ្មោះសេង អាន លើកិច្ចសន្យាផ្ទេរសិទ្ធិចុះថ្ងៃទី៣១-០៣-៩៤ ហើយសំណូមពរឱ្យតុលាការធ្វើកោសល្យវិច្ច័យ និងធ្វើ បដិកោសល្យវិច្ច័យលើស្នាមមេដៃនេះ ។ ប៉ុន្តែតាមលទ្ធផលកោសល្យវិច្ច័យ និងលទ្ធផលបដិកោសល្យវិច្ច័យ បញ្ជាក់ថាស្នាមមេដៃ ដែលដាក់ឈ្មោះសេង អាន ពិតជាស្នាមមេដៃរបស់អ្នកស្រីសេង អាន ប្រាកដមែន ។ ដូច្នេះដើមចោទត្រូវអនុវត្តកិច្ចសន្យាចុះថ្ងៃទី៣១-០៣-៩៤ តាមមាត្រា២២ និង២៩ នៃក្រិត្យ- ច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី២៨-១០-៨៨ ។

-យល់ឃើញថា ការណ៍ដែលមេធាវីដើមចោទ លើកឡើងនៅពេលសវនាការនេះថាកិច្ចសន្យាផ្ទេរសិទ្ធិដីចុះថ្ងៃទី៣១-០៣-៩៤ ធ្វើឡើងពុំត្រឹមត្រូវតាមតម្លៃដីនៅពេលនោះទេ ពីព្រោះនៅពេលនោះតម្លៃដីទំនាស់មានដល់ទៅជាង៩០.០០០បាត ហើយសុំបដិសេធកិច្ចសន្យានេះប្រគល់ប្រាក់ឱ្យចុងចម្លើយវិញ ឬក៏សុខចិត្តបែងចែកដី ពាក់កណ្តាលឱ្យចុងចម្លើយនោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះ

លោកមេធាវីពុំមានភស្តុតាងណា ថាការលក់ទិញនៅពេលនោះដីទំនាស់មានតម្លៃខ្ពស់ជាងតម្លៃដែលព្រមព្រៀងនៅក្នុងលិខិតផ្ទេរសិទ្ធិដីទេ ។ ម្យ៉ាងទៀតចុងចម្លើយក៏ពុំព្រមទទួលយកប្រាក់វិញ និងពុំព្រមបែងចែកដីជាពីរចំណែកតាមសំណូមពររបស់មេធាវីដើមចោទដែរ ។

-យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ១៣(ក) ចុះថ្ងៃទី១១-០៣-០២ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលើកទី២លេខ២៥២ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០២ របស់ លោកឌុច រ៉ាត់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៣(ក) ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០៛ ដែលលោកឌុច រ៉ាត់ បានបង់គឺ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡា បញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛

បង្គាប់ឲ្យលោកឌុច រ៉ាត់ បង់ពន្ធសមាមាត្រ១% លើតម្លៃដីទំនាស់ ។

៤-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ ។